# សិក្ខាសាលាស្តីពី គម្រោងផ្សព្វផ្សាយព័ត៌មានជូនជនរងគ្រោះ
# ថ្ងៃសុក្រ ទី០៧ ខែសីហា ឆ្នាំ២០០៩

កាលពីថ្ងៃសុក្រ ទី០៧ ខែសីហា លោកជំទាវបណ្ឌិត **ហេឌ្លិន ចាទីស** ប្រធានអង្គភាពជនរងគ្រោះនៃ អ.វ.ត.ក បានមានប្រសាសន៍ក្នុងឱកាសបើកសិក្ខានេះថា៖ " ខ្ញុំមានសេចក្តីសោមនស្សរីក-រាយណាស់ ដែលក្រុមការងារផ្សព្វផ្សាយថ្មីរបស់យើង បានធ្វើការងារ ដោយអស់ពីកម្លាំងកាយចិត្ត ក្រោមការដឹកនាំរបស់លោក **នៅ ភាស៊ី** រួមជាមួយអង្គការនានាដែលបានធ្វើការងារនេះយ៉ាងសកម្ម" ។

មានអ្នកចូលរួមប្រមាណ ៧០នាក់ដោយរួមទាំងបុគ្គលិកអង្គភាពជនរងគ្រោះ អ្នកតំណាងមកពីអង្គការជាង២០ មេធាវី និងអ្នកស្រាវជ្រាវ បានចូលរួមក្នុងសិក្ខាសាលានេះដោយមានកិច្ចសហការឧបត្ថម្ភ ពីអង្គភាពជនរងគ្រោះ និងគណៈកម្មាធិការប្រព្រឹត្តិកម្មនៃអង្គការ-សមាគមការពារសិទ្ធិមនុស្សនៅកម្ពុជា។

លោក **នៅ ភាស៊ី** អ្នកសម្របសម្រួលកិច្ចការងារផ្សព្វផ្សាយនៃអង្គភាពជនរងគ្រោះ ណែនាំឲ្យស្គាល់បុគ្គលិកថ្មីផ្នែកផ្សព្វផ្សាយចំនួន៦រូប លោកបានធ្វើបទបង្ហាញស្តីពីយុទ្ធសាស្ត្រកិច្ចការផ្សព្វផ្សាយដ៏មានមហិច្ឆតាខ្ពស់ សំដៅជួយសម្រួលក្នុងការចូលរួមរបស់ជនរងគ្រោះទៅកាន់តុលាការ និងបង្កើតវេទិកាតាមតំបន់សម្រាប់ដើមបណ្តឹងរដ្ឋប្បវេណី និងរៀបចំបណ្តាញនៅតាមខេត្តក៏ដូចជា ការផ្សព្វផ្សាយព័ត៌មានតាមរយៈប្រពន្ធ័ផ្សព្វផ្សាយ។ គម្រោងការងារផ្សព្វផ្សាយទាំងនោះ គឺធ្វើឡើងដើម្បីធានាឲ្យជនរងគ្រោះទទួលបានព័ត៌មានថ្មីៗស្តីពីការវិវឌ្ឍន៍របស់ អ.វ.ត.ក ។
លោកជំទាវបណ្ឌិត **ហេឌ្លិន ចាទីស** បានរាយការណ៍ថា "រហូតមកដល់ចុងខែកក្កដានេះយើងបានទទួលទម្រង់បែបបទព័ត៌មានជនរងគ្រោះចំនួន ៤០៧២ ច្បាប់ ដែលក្នុងនោះមាន ២១៣៦ ជាពាក្យបណ្តឹងធម្មតា និង១៨៧៦ ជាពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី " ។

លោក **រាជ សម្បត្តិ** ប្រធានផ្នែកកិច្ចការសាធារណៈនៃ អ.វ.ត.ក បានធ្វើបទបង្ហាញ និងផ្តល់ឱកាសដល់អ្នកចូលរួមលើកជាសំណួរ និងផ្តល់ចម្លើយយ៉ាងក្បោះក្បាយស្តីពីការងារអង្គភាពរបស់គាត់។ អង្គការនីមួយៗបានផ្តល់នូវបទបង្ហាញខ្លីៗស្តីពីគម្រោងសកម្មភាពការងារផ្សព្វផ្សាយរបស់ពួកគេ ហើយលោកស្រី Mychele Balthazard បេក្ខជនបណ្ឌិតនៃសាកលវិទ្យាល័យ Tulane បានបង្ហាញទិន្នន័យស្តីពីការងារផ្សព្វផ្សាយទាក់ទងទៅនឹង អ.វ.ត.ក ។

នៅពេលរសៀល ក្រុមពិភាក្សាតូចៗបានផ្តល់យោបល់គ្នាពីគម្រោងសកម្មភាពដូចខាងក្រោម៖

- រៀបចំវេទិកាតាមតំបន់ចំនួន៤ សំរាប់អ្នកដែលសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង០០២ ឬដាក់ពាក្យបណ្តឹងឲ្យបានចប់មុនឆ្នាំ២០០៩ ។

- សហប្រតិបត្តិការរវាងអង្គភាពជនរងគ្រោះ និងអង្គការអន្តរការីនានា ដើម្បីទាក់ទងទៅអ្នកដែលបានដាក់ពាក្យបណ្តឹងមិនទាន់មានព័ត៌មានពេញលេញ។

- ធានាឲ្យបានតំណាងផ្នែកច្បាប់ដែលល្អបំផុតសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំ រឿង ០០២

- បង្កើតបណ្តាញចែកចាយព័ត៌មានតាមតំបន់ដើម្បីឲ្យដើមបណ្តឹងរដ្ឋប្បវេណី និង ជនរងគ្រោះផ្សេងៗដឹងពីការវិវត្តន៍នៃការកាត់ក្តីរបស់អ.វ.ត.ក។

ក្នុងសុន្ទរកថាបិទសិក្ខាសាលា លោក **សុខ សំអឿន** ប្រធានសម្របសម្រួលនៃអង្គការ CHRAC និងជានាយកប្រតិបត្តិនៃអង្គការ CDP បានធ្វើការកាត់សំគាល់ថា ការចូលរួមរបស់ជនរងគ្រោះគឺមានសារៈសំខាន់ខ្លាំងណាស់ និងជាជោគជ័យសម្រាប់ អ.វ.ត.ក ។

សិក្ខាសាលានេះអាចធ្វើទៅបាន ក៏អាស្រ័យដោយមានការគាំទ្រផ្នែកហិរញ្ញវត្ថុពីកិច្ចសហប្រតិ-បត្តិការបច្ចេកទេសអាល្លឺម៉ង់ រួមនឹងការឧបត្ថម្ភ និងផ្តល់សម្ភារៈ ពីគណៈកម្មាធិការប្រព្រឹត្តិកម្មនៃអង្គការ-សមាគមការពារសិទ្ធិមនុស្សនៅកម្ពុជា និងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។

សម្រាប់ព័ត៌មានបន្ថែមសូមទាក់ទងៈ

លោក **នៅ ភាស៊ី**

អ្នកសម្របសម្រួលកិច្ចការផ្សព្វផ្សាយនៃអង្គភាពជនរងគ្រោះ

ទូរស័ព្ទលេខៈ ០១២ ៨១៨ ៩៣៥

លោក **ឌីម សុវណ្ណារុំ**

មន្ត្រីទទួលទទួលបន្ទុកព័ត៌នៃ អ.វ.ត.ក

ទូរស័ព្ទលេខៈ ០១២ ៤៨៨ ០៩៤

ថ្ងៃទី១១ ខែសីហា ឆ្នាំ២០០៩